ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ: ២០៧៩ អ.ក
ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០
សាលក្រមលេខ: ៩៥ "ច"
ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ០៩:០០ នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**មេធាវី**

លោក [redacted] មេធាវីការពារក្ដីឱ្យជនជាប់ចោទឈ្មោះ [redacted] គួហ៊ុម

លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គួហ៊ុម

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ: **២០៧៩ អ.ក** ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទៈ

ឈ្មោះ [redacted] **គួហ៊ុម ហៅ រស់** ភេទប្រុស អាយុ ២៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន មានទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងឈូក សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] គួហៀង (ស្លាប់) ម្ដាយឈ្មោះ [redacted] សុខាសំបូរ (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ)។

-ជាប់ចោទពីបទៈ **រំលោភលើទំនុកចិត្ត និងក្លែងបន្លំឯកសារ** ប្រព្រឹត្តនៅភូមិព្រែកទន្លាប់ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីខែសីហា ឆ្នាំ២០២០ តាមមាត្រា ៣៩១, ៣៩២ និងមាត្រា ៦២៦, ៦២៧ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វិសាល** ភេទប្រុស អាយុ ៣២ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ៤១R ផ្លូវលេខ០២ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

## ដំណាលរឿងហេតុមានដូចតទៅ៖

កាលពីខែសីហា ដល់ដើមខែធ្នូ ឆ្នាំ២០២០ នៅចំណុចភូមិព្រែកទន្លាប់ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្ដាល ឈ្មោះ [redacted] គួហ៊ុម ហៅ រស់ ដែលជាប្រធានផ្នែកលក់នៅក្រុមហ៊ុន KH LAND បានទទួលប្រាក់ពីអតិថិជនដែលបានបង់សេវាំរំលស់ថ្លៃដីឡូត៍តាមរយៈការវេរលុយតាមវីង សុរបជាទឹកប្រាក់ ៣៤,៨១៣$ (បីម៉ឺនបួនពាន់ប្រាំបីរយដប់ដឹ) ដុល្លារអាមេរិក ហើយជននេះមិនដាក់ប្រាក់វេរចូលក្រុមហ៊ុនទេ ដោយយកប្រាក់នោះទៅចាយវាយជាប្រយោជន៍ផ្ទាល់ខ្លួនអស់ ហើយនៅក្នុងការចេញវិក័យប័ត្រឱ្យអតិថិជនម្ដងៗ ជននេះបានប្រើប្រាស់វិក័យបត្រ និងត្រាក្លែងក្លាយឱ្យទៅអតិថិជន។ លុះក្រោយមកក្រុមហ៊ុនបានឆែករកមើលទឹកប្រាក់ចំណូលទើបដឹង

វិក័យបត្រ និងត្រាក្លែងក្លាយឱ្យទៅអតិថិជន។ លុះក្រោយមកក្រុមហ៊ុនបានឆែករកមើលទឹកប្រាក់ចំណូលទើបដឹងថាមានការបាត់បង់ទើបតំណាងក្រុមហ៊ុនដាក់ពាក្យបណ្តឹង ហើយសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនជននេះតែម្តង។ ក្រោយការឃាត់ខ្លួន និងសាកសួរជននេះបានសារភាពថា ខ្លួនពិតជាទទួលបានប្រាក់ពីអតិថិជនប្រាកដមែន គឺជាប្រាក់សម្រាប់បង់ចូលក្រុមហ៊ុនសរុបចំនួន ២៧,៥៣៧$ (ពីរម៉ឺនប្រាំពីរពាន់ប្រាំរយសាមសិបប្រាំពីរ) ដុល្លារ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

## សាលាដំបូងខេត្តកណ្តាល
## យល់ឃើញថា

១-តាមចម្លើយរបស់ជនជាប់ចោទ តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងតាមការពិនិត្យឯកសារនានានៅក្នុងសំណុំរឿងឃើញថា គឺពិតជាមានអង្គហេតុដូចការចោទប្រកាន់របស់តំណាងអយ្យការដែលបានចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] គួហ៊ីម ហៅ រស់ ពីបទៈ រំលោភលើទំនុកចិត្ត និងក្លែងបន្លំឯកសារប្រព្រឹត្តនៅភូមិព្រែកទន្លាប់ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីខែសីហា ឆ្នាំ២០២០។

២-ជនជាប់ចោទឈ្មោះ [redacted] គួហ៊ីម ជានីតិជន ហើយជនជាប់ចោទមានស្មារតី និង សមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនចំពោះមុខច្បាប់ពោល គឺជនជាប់ចោទមិនមានសញ្ញាណណាមួយដែលបង្ហាញថាជនជាប់ចោទមានសតិវិបល្លាសស្មារតី ក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយដែលជាហេតុនាំមិនអោយមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនឡើយ។

៣-អំពើរបស់ជនជាប់ចោទៈ

៣-១តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គួហ៊ីម នៅដំណាក់កាលចៅក្រមស៊ើបសួរបានឆ្លើយថាកាលពីខែកញ្ញា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ខ្លួនបានយកលុយពីអតិថិជនដែលបង់រំលោះសេវាថ្លៃដីឡូតិ៍របស់ក្រុមហ៊ុន ខេ អេច លែន ពីអតិថិជនចំនួន ០៤នាក់ ចំនួន ២៧៥៣៤$ (ពីរម៉ឺនប្រាំពីរពាន់ប្រាំរយសាមសិបបួន) ដុល្លារអាមេរិក ចំពោះលុយ ២២៩៥៧$ (ពីរម៉ឺនពីរពាន់ប្រាំបួនរយហាសិបប្រាំពីរ) ដុល្លារអាមេរិក ខ្លួនពុំមានចេតនាយកលុយក្រុមហ៊ុនទេ ព្រោះខ្លួនអាងថាខ្លួនមានដីស្រែយកទៅបញ្ចាំដើម្បីយកលុយសងក្រុមហ៊ុនវិញ ហើយខ្លួនក៏មានចិត្តមួយទៀតធ្វើវិក័យប័ត្រក្លែងក្លាយទុកទទួលប្រាក់ពីអតិថិជន។ ខ្លួនទទួលស្គាល់ថាខ្លួនពិតជាបានយកលុយក្រុមហ៊ុន ខេ អេច លែន ចំនួន ២៧៥៣៤$ (ពីរម៉ឺនប្រាំពីរពាន់ប្រាំរយសាមសិនបួន) ដុល្លារអាមេរិក ពិតប្រាកដមែន តែខ្លួននឹងសងទៅក្រុមហ៊ុនវិញគ្រប់ចំនួន។

៣-២តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិសាល នៅដំណាក់កាលនគរបាលយុត្តិធម៌បានឆ្លើយថានៅក្នុងខែសីហា ឆ្នាំ២០២០ ក្រុមហ៊ុនបានបាត់ចំណូលច្រើន ដូច្នេះបុគ្គលិកក្រុមហ៊ុនបានតេទៅភ្ញៀវភ្ញៀវបានប្រាប់មកវិញថាពួកគាត់បានបង់ប្រាក់ជូនរៀងរាល់ខែមិនដែលខកខាន ដោយមានវិក័យប័ត្រជាសំអាងនិងបានបង្ហាញជូនក្រុមហ៊ុនវិញគ្រប់គ្រាន់ ដោយគាត់បានប្រាប់មកថាផ្ទេរជូនទៅឈ្មោះ [redacted] គួហ៊ីម ជារៀងរាល់ខែ ឈ្មោះ [redacted] គួហ៊ីម គឺជាបុគ្គលិកក្រុមហ៊ុន ខេ អេច លែន ពិតប្រាកដមែន ឈ្មោះ [redacted] គួហ៊ីម ពិតជាឆ្លើយថាបានទទួលប្រាក់ពីភ្ញៀវជារៀងរាល់ខែពិតប្រាកដមែន ហើយឈ្មោះ [redacted] គួហ៊ីម បានយកលុយក្រុមហ៊ុន



Scanned with CamScanner

ទៅប្រើជាប្រយោជន៍ផ្ទាល់ខ្លួន ចំពោះបង្កាន់ដៃទទួលប្រាក់ និងត្រាដែលឈ្មោះ [redacted] គូហ៊ីម បញ្ជាក់ជូនទៅអតិថិជនក៏មិនមែនជារបស់ក្រុមហ៊ុនឡើយ។

តាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការពិនិត្យភស្តុតាងនានាមានភាពស៊ីសង្វាក់គ្នានាំឱ្យតុលាការជឿបានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តនូវអំពើរំលោភលើទំនុកចិត្ត និងក្លែងបន្លំឯកសារ ដូចការចោទប្រកាន់របស់តំណាងអយ្យការពិតប្រាកដមែន។

៤-យោងតាមចំណុចទី៣ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះឃើញថា បច្ច័យទាំងនេះគឺកើតចេញពីអំពើរបស់ជនជាប់ចោទដោយផ្ទាល់ ដែលតម្រូវឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួន។

៥-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង គឺអាចបញ្ជាក់បានថាជនជាប់ចោទពិតជាបានយកលុយរបស់ក្រុមហ៊ុនទៅប្រើជាប្រយោជន៍ផ្ទាល់ខ្លួន និងបានធ្វើវិក័យបត្រក្លែងក្លាយជូនអតិថិជនពិតប្រាកដមែន ដូចនេះគឺអាចបញ្ជាក់ថាជនជាប់ចោទពិតជាបានដឹងនូវចរិកគ្រោះថ្នាក់នៃអំពើល្មើសដោយដឹងច្បាស់ថាលុយនោះមិនមែនជារបស់ខ្លួន ប៉ុន្តែនៅតែមានឆន្ទៈក្នុងការប្រព្រឹត្តអំពើនេះរហូតដល់មានការឃាត់ខ្លួនពីសមត្ថកិច្ច ហេតុដូច្នេះសកម្មភាពអាចបញ្ជាក់ពីធាតុអត្តនោម័តរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើល្មើសរបស់ខ្លួន។

៦-អំពើរបស់ជនជាប់ចោទជាអំពើមួយដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយរបស់សង្គម ផ្ទុយនឹងមាត្រា ៣៩១, ៣៩២, ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការធ្វើការប្រកាសទោសឱ្យទទួលខុសត្រូវតាមបញ្ញត្តិនៃមាត្រាខាងលើ។

៧-ការសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខៈ ២៦៥ ដកសព ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ទុកនៅជាបានការដដែល គប្បីតុលាការសម្រេចផ្តន្ទាទោសជននោះតាមកំណត់ច្បាប់។

៨-លោក [redacted] ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] គូហ៊ីម បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្ញុំបាទត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើរំលោភលើទំនុកចិត្ត និងក្លែងត្រារបស់ក្រុមហ៊ុនក្នុងការទទួលប្រាក់ពីអតិថិជនរបស់ខ្លួនដែលមានទឹកប្រាក់ចំនួន ៣៤៨១៣$ (បីម៉ឺនបួនពាន់ប្រាំបីរយដប់បី) ដុល្លារអាមេរិក ដោយយកទៅប្រើប្រាស់ជាប្រយោជន៍ខ្លួន ជាការពិតចំពោះទឹកប្រាក់ដែលកូនក្តីខ្ញុំបាទបានទទួលពីអតិថិជន គឺមិនមែនដូចអ្នកតំណាងក្រុមហ៊ុនលើកឡើងនេះ ហើយទឹកប្រាក់ដែលកូនក្តីខ្ញុំបាទបានទទួលពីអតិថិជនក៏ពុំមានចេតនាគេចវេះសងប្រាក់ទៅក្រុមហ៊ុនវិញនោះទេ ពោលគឺមានការយឺតយ៉ាវក្នុងការទូទាត់ ចំពោះការចោទប្រកាន់ថាកូនក្តីខ្ញុំបាទក្លែងបន្លំគឺកូនក្តីខ្ញុំពុំមានចេតនាធ្វើឱ្យខូចប្រយោជន៍ទៅដល់ក្រុមហ៊ុននោះទេ ពោលគឺកូនក្តីខ្ញុំបាទធ្វើដើម្បីជាប្រយោជន៍ជូនក្រុមហ៊ុន ដោយយល់ឃើញថានៅពេលអតិថិជនមកបង់ប្រាក់តែងចង់បានវិក័យប័ត្រ ហើយអតិថិជនមកបង់តែថ្ងៃសម្រាកទើបកូនក្តីខ្ញុំបានធ្វើវិក័យបត្រមួយទៀតដើម្បីងាយស្រួល សរុបបញ្ជាក់ថាកូនក្តីខ្ញុំបាទពុំមានចេតនាប្រព្រឹត្តអំពើរំលោភលើទំនុកចិត្ត និងក្លែងត្រារបស់ក្រុមហ៊ុននោះទេ អាស្រ័យហេតុនេះ សូមតុលាការមេត្តាពិចារណា និងយល់ដឹងដល់ការដឹងខ្លួន ទទួលស្គាល់កំហុស ដោយអចេតនារបស់គាត់ ហើយណាមួយគាត់មានសុខភាពមិនល្អតាំងពីតូចមក សូមតុលាការពិចារណាដល់ការគ្មានចេតនាប្រព្រឹត្តគ្មានបទល្មើស និងអនុញ្ញាតឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទដើម្បីគាត់មានលទ្ធភាពអាចធ្វើការងារ និងមានប្រាក់ដើម្បីសងទៅក្រុមហ៊ុនវិញ។

៩-មានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] គូហ៊ីម ហៅ រស់ ភេទប្រុស អាយុ ២៩ឆ្នាំ ពីបទៈ រំលោភលើទំនុកចិត្ត និងក្លែងបន្លំឯកសារ ប្រព្រឹត្តនៅភូមិព្រែកទន្លាប់ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីអំឡុងខែសីហា ដល់ដើមខែធ្នូ ឆ្នាំ២០២០ តាមមាត្រា ៣៩១ ៣៩២, ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

១០-ដើមបណ្តឹងរដ្ឋប្បវេណីទាមទារប្រាក់ដើមចំនួន ២៨៣៨២$ (ពីរម៉ឺនប្រាំបីពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន ៨០០០$ (ប្រាំពាន់) ដុល្លារអាមេរិក គប្បីតុលាការពិចារណា។

១១-ជនជាប់ចោទឈ្មោះ [redacted] គូហ៊ីម បានសំណូមពរឱ្យតុលាការលើកលែងចោទប្រកាន់ដល់រូបខ្លួនផង ខ្លួនដឹងនូវកំហុសហើយ។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] គូហ៊ីម ហៅ រស់ ដែលមានអត្តសញ្ញាណដូចខាងលើ ដាក់ពន្ធនាគារកំណត់ **០១ (មួយ) ឆ្នាំ អនុវត្តទោសដាក់ពន្ធនាគារចំនួន ០៨ (ប្រាំបី) ខែ ទោសសល់ពីនេះព្យួរ** ពីបទៈ **រំលោភលើទំនុកចិត្ត និងក្លែងបន្លំឯកសារ** ប្រព្រឹត្តនៅភូមិព្រែកទន្លាប់ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីខែសីហា ឆ្នាំ២០២០ តាមមាត្រា **៣៩១, ៣៩២, ៣២៦** និងមាត្រា **៣២៧** នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] គូហ៊ីម ហៅ រស់ សងប្រាក់ដើមចំនួន ២៨៣៨២ (ពីរម៉ឺនប្រាំបីពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក និងសំណងការខូចខាតដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិសាល តំណាងឱ្យក្រុមហ៊ុន ខេ អេច លែន ចំនួន ១០.០០០.០០០៛ (ដប់លាន) រៀល ការទាមទារលើសពីនេះបដិសេធចោល។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

-ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍៨រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កណ្តាល,ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]